ឯព្រះបិតា សែនសោយសោកា ពិលាបលន់លង់
អ្នកយកអាហារ ត្រកាលផ្ចិតផ្ចង់ អ្នកតែងផ្គត់ផ្គង់
ឲ្យបរិភោគ្គា ។

ហើយអ្នកផ្ដែផ្ដាំ ឲ្យបងនៅចាំ ប្អូនស្ងួនពុំងា
នៅខ្ទមទៀបផ្នែ គម្ពីរផលសា ទើបអ្នកយាត្រា
នាំព្រះជននី ។

ហិចហែលគង្គា ចម្លងមាតា ពុំយល់ទិសទី
ងងឹតសោតសល់ នោះហេតុព្យេរពី ព្រេងតាមមកខ្មី
នឹងឲ្យឃ្លាតឃ្លា ។

២២៥ ពីព្រះមាតា បិតានោះណា មានព្រានមច្ឆា
ចូលមកដូចផល់ យល់យើងទ្វេហារ ចាប់យកយាត្រា
នានាំផល់អាយ ។

ព្រានពីបរិសុទ្ធ យកយើងជាបុត្រ ហើយនាំមកថ្វាយ
ចូរអ្នកស្ដែងស្ដាប់ សាសព្ទនិយាយ បងថ្លែងប្រាប់ប្រាយ
ដំណើរនេះហោង ។

ជ័យទត្តកុមារ បានស្ដាប់អស់រាចំ ដំណើរទំនង
ទើបអ្នកសោយសោក អមោក្សកន្លង ទាំងប្អូនទាំងបង
ពិលាបឥតស្បើយ ។

ទើបអ្នកថ្លែងថា ឱយើងកំព្រា ព្រាត់ព្រះមេហើយ
យើងសឹងនៅក្មេង ពុំដឹងពិចឡើយ បាក់យើងគោះតើយ
នឹងគុណមាតា ។



ព្រះរៀមឆ្លើយស្នង ថាអ្នកមាសបង យើងសឹងប្រាថ្នា
បើយើងបានសុខ ទៅមុខហើយណា នៅមានជន្មា
យើងរកអ្នកហោង ។

២៣០ ទើបអនុជា ផ្ដណឹងទៀតថា ដូចម្ដេចអ្នកបង
ព្រះវរបិតា ថ្លៃថ្លាកន្លង មាតាស្នេហ៍ស្នង
នោះនាមឈ្មោះអ្វី? ។

ព្រះរៀមឆ្លើយថា ឱប្អូនពុំងា នាមព្រះចក្រី
បងពុំហ៊ានថែង ថ្លាថ្លែងស្រដី ខុសប្រពៃណី
ពុំគួរកាត់ណា ។

អនុជឆ្លើយឆ្លៀត ខះខំរំញទៀត ផណ្ដឹងទៅថា
បើអ្នកពុំប្រាប់ សាសព្ទឡើយណា ធ្វើម្ដេចប្អូនភ្ងា
បានដឹងសេចក្ដី ។

ព្រះរៀមឧត្តម យល់ប្អូនខិតខំ សាកសួរអំពី
បិតាមាតា ថ្លៃថ្លាធិបតី ទើបអ្នកឆ្លើយ
ទុកលើសិរសា ។

ផ្ទោះថ្កានព្រះបាទ ព្រះបរមនាថ ព្រះវរបិតា
ទើបអ្នកចេញថែង ថ្លាថ្លែងប្រាប់ថា នាមព្រះពជា
ហៅក្រុងសុកមិត្រ ។

២៣៥ ព្រះមាតា អ្នកតែងរក្សា យើងទាំងពីរពិត
នាមនាងកេសនី មេត្រីស្នេហ៍ស្និទ្ធ យើងពីរគួរគិត
គុណព្រះមាតា ។

ពជបុត្រពីរពង្ស សំណោះត្រេកត្រង់ ទៅអែកកាន់គ្នា
ឯនាងទេវី ក្សត្រីថ្លៃថ្លា នៅក្នុងក្រឡា
បន្ទំខែនទី ។

នាងផ្ទៀងព្រះកាណ៌ ស្ដែងស្ដាប់អស់អាថ៌ សម្ដែងសម្ដី
ដំណើរទំនង ដើមទងពិតពី រម្យពជបុរី
មាតាបិតា ។

នាងអរចៅពេ៉ា ស្ទះរត់ចេញទៅ ព្រះហស្ដប្រកា
ឱបអង្គពជបុត្រ ពិសុទ្ធថ្លៃថ្លា នាងទួញថ្លែងថា
ឱកូនថ្លើមថ្លៃ ។

អញឯងហើយណា ជាតិជាម្ដាយបា មិនអ្នកដទៃ
ម្ដាយទួញរកអ្នក ឥតអាក់មួយថ្ងៃ ម្ដាយតែងសង្វៃ
សង្រេងខ្លោចផ្សា ។

២៨០ ឱកូនកល្យាណ កូនអើយម្ដាយស្មាន បាក្ស័យជន្មា
និព្វនៅទៀបផ្នូរ គម្ពីរផលសា មិនពឹងជាបា
រស់រូបជីវី ។

ឱកូនកំព្រា ម្ដាយបានយល់បា កាលក្នុងរាត្រី
ម្ដាយដឹងដោយដាន បាបានស្រដី ថានាងកេសនី
ជាព្រះមាតា ។

ម្ដាយឯងជាតី ឈ្មោះនាងកេសនី មែនដូចបាថា
កុំបាគិតផ្ទៃ សង្ស័យឡើយណា អញជាមាតា
បង្កើតបាហោង ។



នាងនាថជាយា ឱបអង្គកុមារ ព្រះហស្ដត្រកង
ដាក់ដល់លើភ្លៅ ចៅពេ៉ាកន្លង អរហើយយំផង
ជោរផលនេត្រា ។

ពជបុត្រត្រអាល ពីរពង្សពិសាល ភ្ញាភ្ញាក់អង្គា
ស្ទុះរត់ចេញខ្លី ថាស្រីនេះណា ពេនមកមុខា
យល់អង្គិត ។

២៨៥ យើងពីរនេះណា ពុំបានស្គាល់ភ្នា នេះកើតហេតុអ្វី
យើងមិនសម្គាល់ ទាំងយប់រាត្រី ថាជាជននី
យល់ពុំគួរការណ៍ ។

នាងយល់ជាបុត្រ បម្រះស្ទុះរត់ ចេញចាកនាងនាថ
ទើបនាងចៅពេ៉ា លោមហៅកុមារ ហៃកូនសង្សារ
រង់ម្ដាយស្រដី ។

ម្ដាយឯងបំពោះ ដាក់ជាហៅឈ្មោះ នាងកេសនី
កុំបាប្រកែក អល់អែកសេចក្ដី បារម្ភនឹងអ្វី
មន្ទិលសង្កា ។

ហៃអ្នកមាសម្ដាយ ឈប់នៅនិយាយ មួយម៉ាត់សិនពា៉
កុំបាភិតភ័យ សង្ស័យចិន្ដា ម្ដាយពុំមុសា
ឲ្យអាស្រូវក្រៃ ។

ឱកូនមាសអើយ បាពុំមកឡើយ សមម្ដាយនឹងក្ស័យ
ជីវិតសោះសូន្យ ណាកូនមាសថ្លៃ តាំងអំពីថ្ងៃ
នេះឯងកូនអើយ ។

២៥០ កុមារឮជាក់ ទាំងពីរអង្គអ្នក មាតាហៅហើយ
ទើបវិលវិងថ្កាន សងសារិនឆ្លាស់ឆ្លើយ ចូលពិតបើ្ដើយ
ក្រាបក្រោមបាទា ។

ឯព្រះជននី ឱបបុត្រទាំងទ្វី សែនសោយសោកា
ទ្រង់ព្រះកន្សែង ថ្លាថ្លែងទូញថា ឱកូនកំព្រា
កំសត់ម្តាយអើយ ។

ម្តាយបានយល់កូន ពន្លកខ្ទឹមខ្លួន ទ្រង់ម្តាយបានស្បើយ
ទុក្ខសោកស្រាកស្រាល ស្រយាលល្វែល្វើយ អ្នកមាសម្តាយអើយ
ម្តាយអរក្តាត់ណា ។

ឱកូនសម្លាញ់ អាពុកបាមិញ តើម្តេចឃ្លាតឃ្លា
ឃើញតែមុខអ្នក ផ្សេងជាក់កាលគ្រា ឯអាពុកបា
ម្តេចបាត់ពុំយល់ ។

កុមារពីរពង្ស សឹងតែទូញទ្រង់ កន្សែងសោកសល់
ក្រាបក្រោមបាទា មាតានិម៌ល ព្រះនេត្រជោរផល
សស្រាក់ទាំងទ្វី ។

ទូញទូលមាតា កាលព្រានមច្ឆា រើសយកពីទី
នាំមកដូចដល់ មណ្ឌលបុរី វត្សរូបបេតី
ជាបុត្រស្នេហ៍ស្និទ្ធ ។

២៥៥ ទូលពីកាលគ្រា ព្រានពីរព្យាបាល រស់រួចជីវិត
ទៅថ្វាយក្សត្រា ថ្លៃថ្លាបពិត្រ ជាខ្ញុំជំនិត
ទ្រង់ព្រះមេត្តា ។



ប្រទានជានាយ មហាគលិកទាំងឡាយ ប្រាំរយគណនា
ក្រាស់ឲ្យមកចាំ ថែទាំកេត្រា បានជួបមាតា
កាលគ្រានេះនៃ ។

នាងនាថទេវី សែនសោយសោកពី លាបលន់ពេកក្រៃ
ផ្ចួតផ្ចើះខ្សឹកខ្សួល រំជួលហឫទ័យ អាសូរបុត្រថ្លៃ
ថ្លែងថ្លឹងពុំបាន ។

ទៀងទូញរៀបរាប់ អស់អាថ៌សាសព្វ ដោយដំណើរប្រាណ
ប្រាប់ព្រះរាជបុត្រ ពិសុទ្ធកល្យាណ ថ្លាថ្លែងដោយដាន
ជួបចូលដល់អាយ ។

២៦០ រីកាលនោះណា អស់អ្នកកេត្រា ផ្ចង់ផ្ចើលប្រញាយ
ភ្ញាក់ភ្ញាក់ទីទៃ គិតភ័យស្ញូវសោយ ដឹងដោយអធិប្បាយ
ដំណើរកិច្ចការ ។

ពាណិជទាំងឡាយ ឈរមើលប្រញាយ យល់រាជកុមារ
ទាំងពីរស្រេចស្រាប់ ប្រចាប់នាងនាថ សំណេះចរចា
ឱបអង្គមកទៅ ។

អស់អ្នកកេត្រា ឆោឡោគ្រប់គ្នា ស្ញើរត្លកសំពៅ
ស្ញូវសព្ទទ្រហឹង ខេទឹងចៅពៅ ថាអ្នកមកនៅ
ម្តេចហ៊ានមើលងាយ ។

វានេះស្នេរស្នា ចិត្តកាចពាលា ពុំគិតក្តៅកាយ
វាតូចបុំណ្ណោះ ចេះមានសហាយ ហ៊ានម្តេចអម្បាយ
គោរចង់តណ្ហា ។

ចិត្តវាធំលន់ ហ៊ានលួចប្រពន្ធ អ្នកនាយកេត្រា
គួរយើងចោមចាប់ ហើយកាប់ក្បាលវា ព្រតវាយកុំត្រា
ប្រណីឡើយនៃ ។

២៦៥ ខ្លះឃាត់ទៅថា កុំអាលគ្រប់គ្នា ជើងងនឹងដៃ
ក្រែងខុសនឹងច្បាប់ ទម្លាប់វិន័យ ក្រែងមហាក្សត្រថ្លៃ
នឹងយកទោសា ។

ខ្លះថាកុំឡើយ បើដោយគិតហើយ គួរយើងគ្រប់គ្នា
ចូលចោមឲ្យជិត កំងបិទផ្លូវវា ហើយយើងលើកគ្នា
ទៅទូលក្សត្រក្សាន្ត ។

អស់អ្នកទាំងនោះ គិតស្រេចដូច្នោះ ហើយទើបប្រុងប្រាណ
ចូលចោមឲ្យជិត ខ្លះអុំសំប៉ាន ទៅប្រាប់ព្រមាន
នាយភាកេត្រា ។

ថាហៃអ្នកអាយ ម្តេចនៅសប្បាយ ពុំគិតកិច្ចការ
ករិយាចោរកាច នឹងពជកុមារ ជួបជាសង្សារ
នោះនៃជាក់ស្បាន់ ។

វាធ្វើពន្លឹក បង្អើលស្មើសឹក នោះនៃយើងទាន់
ទាំងនាយមហាតលិក នៅដេកពាក់ព័ន្ធ អ្នកកុំគ្មេរគ្មាន់
ពាក្យពុំមុសា ។

២៧០ នាយកេត្រស្តាប់ជាក់ ក្រេវក្រោធអួលអាក់ ស្រពោនភក្ត្រា
ឡើងទៅប្រណម្យ បង្គំទូលថា ពុំចេរកុរុណា
ធិរាជជៀសួជ័យ ។



បពិត្រស្មមទាន ក្រាបទូលក្សត្រក្សាន្ត ជ្រាបព្រះហឫទ័យ
ពិតពីកុមារ មោហោកាចក្រៃ ទាំងពីរនាក់នៃ
ធ្វើបរទារកម្ម ។

មែនមានពុតពរ ជាតិជាអន្ធករ មិត្រភ័ក្តិសង្សារ
នឹងភរិយាខ្ញុំ នៅចាំទូកក្តារ ម្តេចធ្វើកិច្ចការ
ឲ្យអង្គអប្រិយ ។

**បទពំនោល**

៨៥ - កាលនោះព្រះបាទចក្រី ស្តេចស្តាប់សម្តី ពាក្យនាយសំពៅទូលថា ។
ស្តេចជ្រាបដូច្នោះហើយណា ទ្រង់ព្រះក្រោធា ហាក់ដូចអគ្គីឆួលឆេះ ។
ថាអេះភគ្គចបុំណ្ណោះ ហ៊ានម្តេចដល់ម្លេះ ពុំគិតជីវិតអន្តរាយ ។
ស្តេចបើកបន្ទូលហៅនាយ ពេជ្ឈឃាតទាំងឡាយ ថាគស់គ្នាយើងមិ្តម្នា ។
ទៅចាប់កូនព្រានមច្ឆា ចងថងវាយវា នោះកុំប្រណីឡើយនៃ ។
៩០ - ហើយនាំចេញឆាប់រ័ៗ យកវាទៅព្រៃ សម្លាប់ទាំងពីរអង្គា ។
ពេជ្ឈឃាតនោះសោតហារហាន (១) បណ្តាំក្សត្រក្សាន្ត ស្រេចនាំកុមារចេញទៅ ។
លុះបានដល់ទ្វារខាងក្រៅ ស្រេចនាំសំដៅ ប៉ុនប៉ងបំបាត់ជីវិត ។
កាលនោះព្រាហ្មណ៍បុរោហិត រត់តាមទៅជិត ស្រេចហើយដណ្តឹងចៅពេ ។
ថាម្នាលពេជ្ឈឃាតកំឡោ នាំអ្នកទោសទៅ សម្លាប់ធ្វើអ្វីអសារ ។
៩៥ - ស្តេចពុំទាន់ពិចារណា ឲ្យយល់ទោសជា ដូចម្តេចក៏ដល់ជីវិត ។
រង់អញដណ្តឹងពិនិត្យ តាមយើងកុំគិត ទុកងារឲ្យអញស្រាប់ហើយ ។
សឹមអញទូលក្សត្រត្រាណត្រើយ ទោសនោះម្តេចឡើយ ក៏ដល់យកចេញទៅតាប់

១ - ច្បាប់ខ្លះថា ពេជ្ឈឃាតក៏សោតហៅហា ។

កាលនោះពេជ្ឈឃាតស្តែងស្តាប់ ស្រេចទើបឆ្លើយប្រាប់ ថាចៅទាំងពីរនេះណា ។
វាលបលួចយកកិរិយា នៃនាយកេត្រា ប្រេចអ្នកគិតនឹងបណ្តោះ ។
១០០ -ទើបព្រានឆ្លើយថាដូច្នោះ ស្តេចពុំពិគ្រោះ ឲ្យដឹងដំណើរសេចក្តី ។
ហើយសឹមសម្លាប់ក្រអ៊ី អ្នកកុំស្រដី រង់ចាំទៅទូលក្សត្រហោង ។
ស្រេចព្រាហ្មណ៍ឡើងទៅដូចបំង ទូលក្សត្រច្បាស់ច្បង ដោយនូវដំណើរសេចក្តី ។
ខ្ញុំសូមឃាត់ព្រះចក្រី ត្បិតខុសវេណី អំពីបុរាណរៀងរាជ្យ ។
ពុំដែលធ្វើនឹងអំណាច សម្លាប់ជាកាច ពិតពុំមានពិចារណា ។
១០៥ ទើបស្តេចស្តាប់ព្រាហ្មណ៍ព្រឹទ្ធា ក្សេមក្សាន្តទ័យា បន្ទូលមធុរវែងខ្នី ។
ថាហៃព្រាហ្មណ៍ព្រឹទ្ធកវី ព្រះស្តែងស្រដី ពីរោះស្មោះសរពេកក្រៃ ។
ទើបស្តេចបន្ទូលថាហៃ គ្នាយើងវៃ ៗ រូសរត់ទៅតាមឆាប់ ៗ ។
អមាត្រក្រាបលាក្រឡាប់ ទៅតាមបង្គាប់ រលះរលាំងខ្មីឃ្មាត ។
១២០ ត្រាស់ប្រើមកយកកុមារ ស្តេចនឹងសួរសារ អំពីអំពើសេចក្តី ។
ពេជ្ឈឃាតនាំវិលវែងខ្មី ថ្វាយព្រះចក្រី នៅក្នុងព្រះរាជរោងរម្យ ។
អស់ព្រាហ្មណ៍ព្រឹទ្ធាជួបជុំ មន្ត្រីតូចធំ គង់គាល់បម្រើដាស់ដា ។
ស្តេចទតទៅយល់កុមារ ទាំងពីរនេះណា ប្រឡាក់នូវឈាមច្រាលផ្កា ។
អស់អង្គឥន្ទ្រិយហ្មងសោ ក្រំក្រៀមកក្រខ្មៅ ក៏រងនូវទុក្ខវេទនា ។
១២៥ ស្តែងស្តេចគិតនឹកអនិច្ចា ក្តៅក្តាត់ឱរា ស្រយុតអស់អង្គក្សត្រក្សាន្ត ។

បទភាគគតិ

២៧៣ កាលនោះព្រះបាទ បន្ទូលសីហនាទ ដណ្តឹងទៅថ្នាន
ថាហៃកុមារ ពិសេសកល្យាណ អញចង់សួរសាន
ដំណើរនៃបា ។



ត្បិតនាយសំពៅ ទូលថាកាលពៅ ទៅចាំកេត្រា
បរទារកម្មកាយ សកោយឫស្យា ភរិយាកេត្រា
មិនមានគិតក្រែង ។
២៧៥ ជាមែនដូច្នេះ កុំចៅវៀចវេះ ចូរចៅសម្តែង
ប្រាយប្រាប់ដោយពិត គំនិតថ្លាថ្លែង ត្បិតយើងចង់ចែង
ចង់ដឹងដើមក្តី ។
កុមារពីរពង្ស ក្រញាបក្រាបឱនអង្គ បង្គំចក្រី
ទៀងទើបទូលថ្កាន សូមទានតូមី ទ្រង់ប្រោសប្រណី
មេត្រីករុណា ។
យើងខ្ញុំសឹងក្មេង ពិតពុំបានស្វែង ចោរចង់គណ្ហា
ពុំបានប្រមាទ វិភទប្រាថ្នា លបលួចភរិយា
ដូចពាក្យប្រក្រតី ។
អញខ្ញុំសន្តោស ពិតពុំមានទោស ដល់ប៉ុនធូលី
សព្វថ្ងៃអនិច្ចា កំព្រាទាំងខ្ញី ព្រាត់ប្រាសជននី
ទៀងទើបបានយល់ ។
ខ្ញុំពុំមុសា ជាក់ជាមាតា អ្នកសោយសោកសល់
ខ្ញុំឱបព្រះមេ ខំតែទប់ទល់ ស្នើរនឹងដាច់ខ្យល់
នៅនឹងកេត្រា ។
២៨០- ស្រាប់តែពេជ្ឈឃាត ធ្វើទុក្ខដល់ខ្នាត ស្នើរក្ស័យជន្មា
ទៅដល់ចាប់ចង វាយផងដេរថា ពុំដឹងអាត្មា
ដល់ប៉ុនកេសី ។

ពង្សពុទ្ធង្កុរ ជាតិជាអម្បូរ ជ្រាបអស់សេចក្តី
ដំណើរកុមារ សងសាសម្តី សម្តែងពាក្យពី
ជួបជូនមាតា ។

ក្សត្រក្សត្រទ្រង់ធម៌ ជ្រួតជ្រាបអស់អាថ៌ ទន់ព្រះទ័យា
ព្រឺព្រួចប្រមាត់ ក្តៅក្តាតខ្លោចផ្សា តានតឹងឱរា
ទង្គឹះខ្សឹកខ្សួល ។

ខំតែតម្រង់ ស្មារតីត្រូវគង់ សំណេះសងសួរ
ថាហៃកុមារ ពិសាលទាំងគូ ពូជពង្សអម្បូរ
ជនកជននី ។

នោះនៅឯណា មួយសោតនាមា នោះតើឈ្មោះអ្វី ?
ចូរពោលប្រាយប្រាប់ រៀបរាប់សម្តី សម្តែងពាក្យពី
អាពុកម្តាយបា ។

២៨៩ រាជបុត្រពីរពង្ស លុតលើកកំបង់ ដាក់លើសិរសា
ហើយទើបទូលថ្កាន សូមទានក្សត្រា វិនោមមាតា
ឈ្មោះនាងកេសនី ។

យើងខ្ញុំពិសុទ្ធ ផ្សៀងដាក់ជាបុត្រ មូលមួយជននី
សូមស្តេចទ្រង់ជ្រាប សភាពសេចក្តី ពាក្យពិតសម្តី
ពិតពុំមុសា ។

ស្តេចស្តាប់លុះឮ ហឫទ័យព្រួចព្រឺ ទន់ទាំងកាយា
ផ្សារខ្លោចក្រៃលែង ដណ្តឹងទៀតថា វិនោមបិតា
នោះតើឈ្មោះអ្វី ? ។



ចូរចៅប្រាយប្រាប់ ដំណើររៀបរាប់ ពីស្រុកទេសទី
តំបន់ស្ថិតស្ថាន បុរាណបុរី គេរ៉ុប្រពៃណី
នោះនៅឯណា ? ។

រាជបុត្របង្គំ ទូលក្សត្រឧត្តម តស្វរសិរសា
បពិត្រស្រុក ព្រះជនកនាមា នេះនៃហោជ៍
ចម្បាកនគរ ។

២៩០ រីព្រះបិតា នោះទ្រង់នាមាំ ចម្រើនព្រះពរ
ខ្ញុំពុំហ៊ានថ្លែង សម្តែងនាមករ ក្បិតខ្លាចភូធរ
ក្រែងពុំមេត្តា ។

ស្តេចស្តាប់ផ្សៀងដាក់ ព្រឺព្រួចភ្ញាក់ភ្ញាក់ តានតឹងឱរា
ស្មើរនឹងបែកថ្លើម ដង្ហើមទ័យា ក្តៅក្តាត់ផ្សាយផ្សា
ឈឺឆ្អៀបអស់អង្គ ។

ស្តេចគិតសន្និះ ហឫទ័យរួសរំះ ដណ្តឹងពូជពង្ស
អនាថអាណិត ក្បិតព្រាត់បាត់បង់ ព្រះនេត្ររលង់
ស្រក់ស្រោចភក្ត្រា ។

ទើបស្តេចខំឆ្លៀត ដណ្តឹងវិញទៀត ជាពីរបីគ្រា
ថាចៅវិសាល ត្រកាលរួសរាំ អ្នកកុំសង្កា
កុំកោតកុំក្រែង ។

ក្បិតយើងចង់ស្គាល់ ពូជដោរៀងរាល់ ចូរចៅចាយថែង
ប្រាយប្រាប់ឲ្យស្មោះ ចំពោះឲ្យស្តែង កុំចៅកោតក្រែង
សន្និះសង្កា ។

២៩៩-ទើបចៅជ័យសែន   នរនាថនរេន្ទ្រ   ក្រាញក្រាបសិរសា
លើកករប្រណម្យ   បង្គំទូលថា   វរនាមបិតា
ឈ្មោះក្រុងសុភមិត្រ   ។

ព្រះអង្គជាក្សត្រ   សោយរាជសម្បត្តិ   ទ្រង់ធម៌សុចរិត
យើងពីរជាបុត្រ   ពិសុទ្ធស្នេហ៍សិទ្ធ   មាតាសោគស្ថិត
នាមនាងកេសនី   ។

ក្សិណក្សត្រត្រកាល   លុះឮអម្បាល   អស់ពាក្យពេចន៍ពី
កុមារទៀងទូល   អម្បរវេណី   នូវនាមបុរី
មាតាបិតា   ។

ស្តេចជ្រាបសព្វគ្រប់   ពុំអាចទល់ទប់   ព្រះហស្តស្រវា
ឱបអង្គរាជបុត្រ   វន្ទត់អង្គា   សែនសោយសោកា
សន្លប់លង់ហោង   ។

អស់មុខមន្ត្រី   យំយល់ភូមី   នូវបុត្រស្នេហ៍ស្នង
អាណិតអនាថ   សល់ខ្វាតកន្លង   សឹងតែយំផង
ផុតផលនេត្រា   ។

៣០០-អស់ស្រីព្រះស្នំ   អករយាយចាស់ទុំ   សឹងសោយសោកា
ប្រណីអាសូរ   អម្បរក្សត្រា   មករងវេរា
ទល់ទុក្ខប្រាសប្រាណ   ។

អស់រាស្ត្រប្រជា   គរគក់ឱរា   ទួញយំស័ព្ទសាន
រនៀបរនេល   រណែណរក្នុងស្ថាន   នឹងទប់ពុំបាន
ឈឺមហាក្សត្រា   ។



កាលនោះពោធី   បានភ្ញាក់ស្មារតី   ស្រេចហើយម្នីម្នា
ស្តេចឲ្យដោះក្តី   ចេញពីបុត្រា   ទាំងពីរអង្គា
រ័ក្សរួមស្នេហ៍ស្និទ្ធ   ។

ស្តេចបន្ទូលថា   អាពុកនេះណា   នាមក្រុងសុភមិត្រ
សព្វថ្ងៃអាពុក   ជាទុក្ខគន់គិត   គុំដែលដាច់ចិត្ត
ដល់មួយរាត្រី   ។

២៩០- ឱកូនសម្លាញ់   ទាំងពីរពោលពេញ   រាងរូបពិសី
បាបានមកនៅ   គាល់ហ្វៅប្រក្រតី   សព្វទិនរាត្រី
អង្វែងយូរហើយ   ។

៣០៩-ម្តេចបាពុំថែង   ពាក្យពេចន៍សម្តែង   ឲ្យដឹងដើមឡើយ
ម្តេចបាលាក់លៀម   នៅស្ងៀមព្រងើយ   ម្តេចបាតោះតើយ
ពិតពុំនាំពា   ។

រាជបុត្រពីរស្តាប់   ទើបទូលប្រាយប្រាប់   ព្រះវរបិតា
បពិត្រព្រះអង្គ   សូមទ្រង់មេត្តា   ខ្ញុំពីរអង្គា
នឹងចាំពុំបាន   ។

គ្សិតខ្ញុំនៅក្មេង   ពុំដឹងផ្សេងៗ   ជាមហាក្សត្រក្សាន្ត
បានសោយសម្បត្តិ   រម្យរដ្ឋពិមាន   ជាតិជាប្រធាន
ឥស្សរសិរសី   ។

កុមារវរវ័តន៍   ក្រាបក្រោមព្រះបាទ   ទួញទូលភូមី
បពិត្រក្សត្រក្សាន្ត   សូពទានប្រណី   អាសូរជននី
និត្យនៅភេត្រា   ។

អ្នកតែងទល់ទុក្ខ ត្បិតពុំយល់មុខ ខ្ញុំជាបុត្រភ្ញា
ស្នើរក្សាជីវិត កាលពេជ្ឈឃាតវា ចាប់ខ្ញុំករុណា
ថ្វាយមហាក្សត្រថ្លៃ ។

៣១០-អាសូរព្រះមេ ម្លេះសមគេដេរ រំលើកដំវាយ
ត្បិតនាយគេត្រា គេជាសហាយ ខ្ញុំកូននិងម្ដាយ
ទាស់ទូលក្សត្រក្សាន្ត ។

ព្រះពោធិសត្វ ស្ដែងស្ដាប់បុត្ររ័តន៍ ស្ដេចជ្រាបដោយផាន
ទើបស្ដេចឲ្យរៀប ប្រុងប្រៀបនូវយាន ស្ដេចនឹងទៅថ្កាន
ទទួលជាយា ។

អស់មុខមន្ត្រី រួសរៀបឃ្មាតខ្មី ដូចព្រះអាជ្ញា
ដោយងារកំណាន់ រួសរាន់ម្ទីម្នា ប្រដាប់ប្រដា
ស្រេចស្រាប់ហើយនៃ ។

រាជយានថ្កល់ថ្កើង ក្លីងក្លស់លើកឡើង បើកបាំងប្រពៃ
ព្រះស្នំស្រីគ្គរ បរិពារក្រាស់ក្រៃ ហែក្សត្រវៀស្ឋជ័យ
អនេកត្រៀបត្រា ។

រាជបុត្រវិសាល គង់យានត្រអាល ហែមុខក្សត្រា
អស់មុខមន្ត្រី សេនីយ៍សេនា ពលច្រើនគណនា
ប្រតិតរៀងរាយ ។

៣១៩ ស្ដេចឆ្ពោះគម្រង់ បានដល់កំពង់ ផ្អើលភ័យរញ៉ាយ
រត់ចេញពពួន ផញួនរបាំយ រំយែករយ៉ាយ
កំពប់មួស្នា ។



ឯនាយសំពៅ រួសរៀបនឹងទៅ ទទួលក្សត្រា
វាយឃ្មោះរំពង អឹងកងគ្រប់គ្នា ចាំមហាក្សត្រា
ស្ដេចចុះមកថ្កាន ។

អស់អ្នកតែត្រា ប្រដាប់ប្រដា ប្រុងប្រៀបគ្រប់ប្រាណ
ចរចេញសំពៅ ចតនៅខាងស្ពាន ស្រេចឡើងទៅថ្កាន
បង្គំក្សត្រា ។

រាជបុត្រវិសាល ពីរពង្សត្រអាល បង្គំទូលថា
បពិត្រព្រះអង្គ សូមទ្រង់មេត្តា អាសូរមាតា
អ្នកតែងទុក្ខទល់ ។

ខ្ញុំនឹងក្រាបលា ទៅមុនក្សត្រា ឲ្យបានយង់យល់
ម្លេះសមព្រះមេ រហែរហល់ សមសោយសោកសល់
សង្រេងសង្រែ ។

ខ្ញុំនាំពត៌មាន ទៀងទូលឲ្យបាន ជ្រាបជាក្សត្រថ្លៃ
ស្ដេចចុះបកស្នូរ ទទួលទៅឰ ឲ្យបានដឹងន័យ
ដំណើរក្សត្រា ។

៣១០ ព្រះពោធិសត្វ បើកបុត្រពីរថ្វាត់ ទៅថ្កានមាតា
នាងនាថទេវី ក្សត្រីថ្លៃថ្លា ត្រេកសោមនស្សា
នឹងបុត្រពីរពង្ស ។

រីឯកុមារ ទៀងទាត់អស់អាថ៌ ពីរក្សត្ររវង្ស
ជាតិជាបិតា រូបរក្សាអង្គ ស្ដេចបានបកទ្រង់
រាជ្យរក្សារដ្ឋ ។

ឥឡូវក្សត្រក្សាន្ត យាងចុះមកថ្កាន ទម្លុយបាល
ទៅសោយសម្បត្តិ រម្យរដ្ឋសីមា ឲ្យបានជួបគ្នា
មួលមួយមេត្រី ។
ក្សិណនោះនាងនាថ ស្តែងស្តាប់កុមារ ឡេងទូលអំពី
ព្រះវៀមច្បាស់ច្បង បានគ្រងបុរី បុរាណវេណី
ក្រុងតក្កសីលា ។
ក្សត្រីវរលក្ខណ៍ អរតេតទុកដាក់ ត្រេកសោមនស្សា
ព្រឺព្រួចព្រះអង្គ ប្រតិយង់រោមា ទន់ទាំងកាយា
ថ្លែងថ្លឹងពុំបាន ។
កាលក្រោយកុមារ ព្រះវរបិតា ចុះពីពជយាន
អស់ស្រីព្រះស្នំ ចោមជុំក្សត្រក្សាន្ត ស្តេចឆ្ពោះទៅថ្កាន
ភេត្រាស្ដឹមស្ដៃ ។
៣២៥ អករយាយចាស់ទុំ នូវស្រីព្រះស្នំ ហែព្រះវេស្សជ័យ
ឡើងលើសំពៅ ចូលទៅកន្សៀ ក្សិណក្សត្រីថ្លៃ
យង់បល់ក្សត្រា ។
នាងអរស្រោកស្រួល រត់មកទទួល ឱបព្រះធាត្រា
ស្តេចយល់ទេវី ក្សត្រីថ្លៃថ្លា ជាក់ជាពនិតា
ឱបអង្គទៅមក ។

## បទព្រហ្មគីតិ

២៨៩ កាលនោះក្សត្របួនប្រាណ ជួបរួបស្ថានក្នុងសំពៅ
សឹងសោយសោកសុបសៅ រួលរាណិតរវោចណោ ។



៣០០ ថាឱបុណ្យមិត្រមាស កាលយើងប្រាសព្រាត់ពីគ្នា
អម្ពូងយូរម្ល៉េះណា ទើបថ្ងៃនេះបានជួបចៅ ។
បងស្មានថាប្អូនស្រី ក្ស័យជីវីសោះសូន្យសៅ
កណ្តាលអគ្រាត្រជ្រៅ ឃើញតែសត្វម្រឹគពាលា ។
ម្តេចមេមាសព្រលឹង នាងនៅនឹងនាយភេត្រា
គ្រាច់គ្រង់ដោយចក្រវាឡ៍ ចេញជួញចូលជួបដល់អាយ ។
នាងនាថឡេងទូញទូល ដោយទំនួលបទនិយាយ
ពីព្រាត់ក្សត្រពណ្ណរាយ នៅទៀបឆ្នេរសាគរា ។
កាលស្តេចហែលជញ្ជូន ទៅយកកូនទាំងទ្វេហារ
ក្រោយនោះអ្នកភេត្រា បើកសំពៅទៅបុរី ។
៣០៥ ចូលចតឈប់ចាំថ្ងៃ ជូនជួបឰអង្គអូនស្រី
ខ្ញុំគិតព្រះចក្រី ក្រែងក្សិណក្ស័យជីពជន្មា ។
ក្សិតខ្យល់ខ្លាំងពន្លឹក ជន់ជោរទឹកលិចពសុធា
នោះនៃទើបអស់ពា- ណិជទាំងឡាយនាំខ្ញុំបក ។
ទើបខ្ញុំបានជួបជួន នឹងកូនស្ងួនគន់ពន្លក
ទាំងពីរចុះមករក ចាំភេត្រាបានបកយល់ ។
នាងទួញទូលក្សត្រក្សាន្ត សោកប្រាសប្រាណអនាថសល់
ព្រះនេត្រជោរផល់ ស្រក់សស្រាក់ស្រោចទាំងទ្វា ។
ព្រះពោធិសត្វសឹង សោកតានតឹងគត់ឱរា
អាណិតអង្គអមិច្ឆា រូចរស់រងវេរាព្រៃ ។

៣១០- ស្តេចទួញហើយរៀបរាប់ ដំណើរប្រាប់សងសម័យ
ប្រាប់កាលក្សត្រជៀសជ័យ ហែលសមុទ្រសាគរ ។
ប្រាប់កាលស្តេចទៅរក បុត្រពន្លកទាំងទ្វេហារ
ពុំយល់ស្ងួនស្សោះសា ហែលវិលមករកប្អូនស្រី ។
សឹងបាត់ស្វាត់ជ្រងំ ក្នុងទុគ៌មជ្រោះគិរី
រត់រកសព្វទិសទី ដង្ហោយហៅសព្វព្រឹក្សា ។
ប្រាប់កាលពីស្តេចស្តែង ត្រាច់វង្វេងឯកអង្គា
ដើរដូចដល់ភារា គក្ខសិលាបុរីរដ្ឋ ។
ប្រាប់កាលព្រះច្បាស់ច្បង បានគ្រប់គ្រងរាជសម្បត្តិ
សមបុណ្យអម្បរក្តាត់ សោពសោយសុខកើតវឡើ ។
៣១៥- ស្តេចប្រាប់គ្រប់ប្រការ ពីកុមារបុត្រទាំងទ្វី
បានមករួមមន្ទីរ ជួនជួបចួលម្លួមួយប្រាណ ។
ស្តេចទួញទៀតពីគ្រា ឱបប្រវាបុត្រកល្យាណ
សោយសោកពុំស្រាកស្រាន្ត ស្ទើរសន្លប់បាត់ស្មារតី ។
សាវដែស្រីព្រះស្នំ គក់ទ្រូងយំយល់ក្សត្រី
នូវព្រះពង្សពោធី សឹងសោយសោកសុវស័ព្ទសាន ។
អក៍វយាយស្រីព្រះស្នំ ចាំចោមជុំជិតក្សត្រក្សាន្ត
ផលនេត្រពុំស្រាកស្រាន្ត ស្រេចបន្ទោទុក្ខសោកសោះ ។
ហើយនាងនាថធីតា ជួបចរចាស្នេហ៍គ្រស្មានស្មោះ
តាំងចិត្តពុំហ៊ានហោះ ទូលសច្ចាស្រេចឥតឆ្គង ។



៣២០-ស្បើយទុក្ខស្បើយទោសា ស្បើយសោកាឥតមានហ្មង
ទាំងពីរក្សត្រច្បាស់ច្បង នូវបុត្រាទាំងពីរពង្ស ។
ក្សត្រប្អូនបរិបូណ៌បាន ម្លួលម្លួយស្ពានសេនបនិត្យគង់
ស្នេហ៍ស្និទ្ធជិតជួញអង្គ និត្យនៅនាកេត្រាជ័យ ។
ឯនាយកេត្រានោះ យល់ដូច្នោះភាំងភិតភ័យ
ដល់ជិតទាំងពីរក្រៃ ក្រែងព្រះអង្គយកទោសា ។
ក្រញក្រាបពុំងើបនៃ ភិតភ័យក្រៃខំទូលថា
សូមទ្រង់ព្រះមេត្តា ទុក្ខជីវិតកាលនេះម្តង ។
ក្បិតខ្ញុំពុំនឹងជាក់ ជាព្រះអគ្គមហេសីច្បង
គិតស្មានជារាស្ត្រផង រើសនាងមកទុករក្សា ។
៣២៥-ស្តេចស្តាប់ពាក្យនាយកេត្រ ទូលពីហេតុគ្រប់ប្រការ
ទ្រង់ឤនបន្ទូលថា ពុំយកទោសព្រះស្តែងឡើយ ។
ទាំងនេះគឺកាឡកច្ឆ មុននាយនាំមកជួល់ហើយ
វិបាកឯងជាត្រើយ នឹងរៀចរេះចៀសពុំបាន ។
ស្តេចទ្រង់ព្រះមេត្តា នាយកេត្រាស្រេចក្សត្រក្សាន្ត
នាំនាងឡើងទៅថ្កាន ប្រាង្គប្រាសាទប្រសើរថ្លៃ ។
លើកនាងនាថឧត្តម ឡើងជាធំប្រសើរក្រៃ
ព្រះស្នំក្រំសាវដៃ ចាំបម្រើពុំឲ្យហ្មង ។
ឯអង្គរចាជ័យសេន បុត្រនរេន្ទ្រជាតិជាច្បង
ស្តែងស្តេចឲ្យស្នប់ស្នង តាមដោយបុព៌ប្រពៃណី ។

៣៣០-ជាឧបរាជា គ្រងសេនាមុខមន្ត្រី
សោយសុខសមសោភី ថ្កើងព្រះយសយល់ប្រពៃ ។
រីឯពជបុត្រា អនុជានោះសោតនៃ
ជ័យទត្តកុមារថ្លៃ លើកជាអគ្គមហាសេនា ។
ធិបតីជាតិជាច្បង លើសកន្លងលែងលោកា
ប្រទេសទៀតនានា សឹងមូលមកនាំសួយរ ។
ភ្នីមាសនូវភ្នីប្រាក់ ច្រើនអន័គ្ឃអនេកក្រៃ
ជាប្រក្រតីសព្វថ្ងៃ សឹងចុះចូលមូលវន្ទា ។
ស្តេចសោយសេពសម្បត្តិ នូវរាស្ត្ររដ្ឋស្រីស្រីង្គារ
សម្រាប់ច្រើនមហិមា ថ្កើងព្រះកេរ្តិ៍កបជោគជ័យ ។
៣៣៨-ព្រះពោធិសម្ភារ តែងរាជការមង្គលក្រៃ
មានមហោស្រពយប់ថ្ងៃ គ្រប់ភ្លេងភ្លាត់ច្រើនដេរដាស ។
ស្តេចទ្រង់ព្រះសទ្ធា មានមេត្តាអាសូររាស្ត្រ
ស្តេចឲ្យទានប្រាក់មាស ពុំដែលដាច់ទិនទិវា ។
ពុំឲ្យហសខាតខាន ដាក់ប្រទានទៀងសព្វគ្រា
ទ្រព្យធនសឹងថ្លៃថ្លា សំពត់អាវបាយចំណី ។
រាស្ត្រទាសទាំងក្នុងក្រៅ ផងផ្លូវព្រៅមូលមកខ្មី
ទទួលទានពោធិ៍ និរន្តរ៍ទៅនៅទៀងទាត់ ។
៣៣៩-ក្សត្រពីរពង្សថ្លៃថ្លា ទ្រង់សទ្ធាពន់ពេកក្កាត់
គោត្តពង្សពោធិសត្វ សាងសន្សំព្រះបារមី ។



**មទកាភគតិ**

៣២៧ ព្រះកាទបុត្រក្រុង- សុភមិត្រពុទ្ធវង្ស ពន្លកជិនស្រី
ស្តេកទ្រង់ទសពិត សុចរិតធម៌ពី បុរាណរេណី
ក្រមក្រឹត្យក្សត្រា ។
ស្តេចទ្រង់សីលប្រាំ អដ្ឋសីលចាំ សព្វទិនទិវា
សង្វេគសង្វាត ស្ទើងស្មាធីភាវនា នៅលើប្រាង្គប្រា-
សាទសព្វរាត្រី ។
ព្រះអង្គក្សត្រក្សាន្ត ស្តេចតែងទូន្មាន សេនាមន្ត្រី
ឲ្យកាន់សីលប្រាំ ចងចាំស្មារតី រាស្ត្ររដ្ឋសោភី
គៀមក្សាន្តសាទរ ។
៣៣០ ព្រះពោធិសត្វ នូវនារីរ័ត្ន សេពសោយបរិបូណ៌
ព្រះយសយល់ថ្កើង រុងរឿងនគរ ឮទូទាំង
លើសលែងលោកិយ ។
អង្វែងយូរលង់ ផងព្រះអង្គ បៀតបៀនបាយី
បុរាណនាយនាំ កាយកម្មពោធិ៍ រំលោងជីវី
ក្សិណក្ស័យផន្លា ។
ទាំងពីរព្រះអង្គ ស្តេចបានទៅគង់ តុសិតសួគ៌ា
សោយសុខសួគ៌ស្ថាន បានជួបជួនគ្នា នូវរាជបុត្រា
ទាំងពីរមូលស្ថាន ។
ព្រះពង្សពោធិ៍- សត្វសាងបារមី អន្ទោលមកផ្ទាន
សេពគកងសីលា ប្រាជ្ញាញេយ្យញាណ លង់លុះប្រមាណ
សពេជ្ញជិនស្រី ។

ព្រះអង្គបានត្រាស់   ជាពុទ្ធច្បងច្បាស់   ផ្ជួបផ្តុំជាតិ
ទេសនាព្រះធម៌   នូវអាថ៌គម្ពីរ   បើកបទបាលី
ត្រាស់ធម៌ទេសនា   ។

៣៣៩-ភិក្ខុអើយអសុ-   ភមិត្រគម្រប់   ជាតិចងវេរា
ចេរវិលវឹងមក   យោនយកជាតិជា   ទេវទត្តនៅឆា
នរកនាយនៃ   ។

វិចៅផ័យទត្ត   កុមារនោះគាត់   យកជាតិវិស័យ
ចេរវិលវឹងជា   មហាអានន្ទនៃ   រងរសធម៌ថ្លៃ
ពីពុទ្ធឱស្ឋ   ។

វិចៅផ័យសែន   កុមារមិញមែន   ចេរវិលវឹងជា
ព្រះមហាពហុល   ផេរផុលប្រាជ្ញា   រំនគីនវណា
ឯទៀតឡើយនៃ   ។

នាងកេសនី   ពិម្ពាថេរី   ជាតិជាកន្សៀ
ពន្លកសពើជ្ញ   ត្រាស់ត្រាច់ញាណញេយ្យ   ឆាងបានទ្រង់ត្រៃ
បិដកថែងចប់   ។

វិព្រះមាតា   អង្គវញេតថា-   គតកើតសអួត
បានជានាងរាក   មាយាគម្រប់   បូលបកសព្វគ្រប់
លុះសវណាគរន៍   ។

៣៤០ វិព្រះបិតា   បង្កើតតថា-   គតគាប់ជាធំ
នាបព្រះបាទស្រី   សុទ្ទោទន៍ឧត្តម   បានមកផ្ជួបជុំ
ជាពុទ្ធបិតា   ។



វិក្រុងសុភមិត្រ   រាជបុត្របវិត្រ   គឺអង្គតថា-
គតឯងបានត្រាស់   ច្បងច្បាស់ប្រាជ្ញា   នាំធម៌ទេសនា
ទូន្មានភិក្ខុផង   ។

សាធុសម្លាយ   ចូរចាំនិយាយ   តំណាលទំនង
ព្រះវង្សពោធិ-   សត្វវិសេសច្បង   អស់អាថ៌នេះហោង
សូរចេម្ល៉េះណា   ។

( ចប់រឿងក្រុងសុភមិត្រតែប៉ុណ្ណេះ )

ក

ក្ងក់ក្ងំ ខ . (ម កនក មាស) ក្អក់ ក្បាច់រំលេចដូចពាក្យថា ក្អក់នាគ ជាដើម ។ ពាក្យនេះក្លាយមកពីពាក្យមគធៈ កនកនោះឯង ។

ក្ងែន ខ , ក្លា , ក្លាហាន ។

ក្សត្រីក្សត្រា (សំ . ក្លាយ) តាមទម្លាប់ខ្មែរប្រើនិយាយដោយសន្មតថា ក្សត្រី ស្តេចស្រី , ក្សត្រា ស្តេចប្រុស , តែតាមសំស្ក្រឹតថា ក្សត្រិយានី ស្តេចស្រី ក្សត្រិយ ស្តេចប្រុស ។

គ

គជេន្ទ្រ សំ . ដំរីធំ , ស្តេចដំរី ។

គម្ភីរា ម · សំ . គម្ពីរ , ជ្រៅ , ទន្លេជ្រៅ ។

ច

ចតុរង្គ ម . សំ . រេហ៍ពល ៤ ពួក (គឺពលសេះ ពលដំរី ពលរថ ពលថ្មើរជើង) ។

ចរចេរ ម . ត្រាច់យូរទៅ , ត្រាច់អស់កាលដ៏យូរ ។

ចាមរ អ . សំ . សែ៎ ។ មួយយ៉ាងទៀតជាឈ្មោះហៅគ្រឿងហែរាជយាន សណ្ឋានដូចផ្លិតសង្ឃរាជាគណៈ កំពូលដែកជា ៣ មានដងវែងសម្រាប់កាន់ហែ ។

ចុងព្រះរាជរោង ខ . ទីសម្រាប់គាល់ហៅស្តេចផែនដី យ៉ាងព្រះទីន័ងទេវាវិនិច្ឆ័យសព្វថ្ងៃនេះ

ឆ

ឆ្នេរនទី ខ . អ ឆ្នេរទន្លេ ។



ជ

ជននី ម . សំ . ស្រីអ្នកបង្កើត , ម្តាយ ។

ជលធី ម . សមុទ្រ , ទន្លេ ។

ជលនេត្រធារា សំ , ទនៃទឹកភ្នែក , ទឹកភ្នែកហូរ ។

ជាត្រី ខ . (?) ជាឈ្មោះល្ខោនបុរាណមួយយ៉ាង តែជួនកាល គេហៅក្លាយទៅជាឆាត្រីតាមសំឡេងសៀមក៏មាន ។

ជីវិតក្សិណក្ស័យ សំ . ក្ស័យជីវិត , អស់ជីវិតស្លាប់ ។

ទ្រុំផលា ( ទ្រុំ ខ. ផលា ម .សំ.) ផ្លែច្រើន, ផ្លែស្តុក ឱ. ព្រៃស្រោង រំលោងបពួតា សឹងទ្រុំផលាទុំរុះពោយរាយ

ឈ

ឈី ខ. ឈឺ, ឈឺចាប់. ឈឺដោយសារ, រួមទុក្ខផង ។ ឱ ទ្រូញយំសព្ទសាិនរនៀលរនេល រណែលក្នុងស្ថាន នឹងទប់ពុំបាន ឈឺមហាក្សត្រា ។

ដ

ដកចន្ទន៍ ១. ម. ផ្តាចន្ទន៍ ក្បាច់ផ្តាចន្ទន៍ ។

ជាស់ទុំ ខ. វេលាចាស់ដេកលក់, វេលាអធ្រាត្រ ។

ដោរ ពិដោ ១. ក្រអូប ក្រអូបសាយ ។

ត

តាទា ម. សំ. ផ្កាយ, ហ្វូងផ្កាយ ។

ត្បូខខ្សាច់ ខ. ផ្នូកខ្សាច់. វាលខ្សាច់ ។

ត្រឡេខគែខ ខ. ផ្លូវបែកជា ៤, ឱ. ផ្លូវត្រឡែងកែង ។

ត្រាណត្រៃយ — ខ. ទីពឹង, ទីពំនាក់ទៅខាងមុខ ។

ត្រៃភព — សំ. ភព ៣ គឺមនុស្សលោក ទេវលោក ព្រហ្មលោក ។

ថ

ថ្មើរទេស — ខ. អ្នកដើរតាមប្រទេស. ថ្មើរជើង. អ្នកដើរជើង ។

ទ

ទន់ភ្លន់ល្វតល្វៃ — ខ. ទន់ភ្លន់តាមរបៀបស្រី គឺទន់ភ្លន់តាមបែបស្រី ។

ទសពិធរាជធម៌ — សំ. ( ម. ទសវិធរាជធម្ម ) ធម៌សម្រាប់ស្តេចមាន ១០ ប្រការ ។

ទិន — ម. សំ. ថ្ងៃ ។ សព្វទិនរាត្រី រាល់ថ្ងៃរាល់យប់ ។

ទុគ៌ត — សំ. ( ម. ទុគ្គត ) អ្នកកំសត់. អ្នកទ័លក្រ ។

ទ្រង់នូវពលា — ខ. ម. ទ្រង់នូវកម្លាំង ។

ន

នភី — ម, ( នភ ) អាកាស . ទីផ្ទៃមេឃ ។

នយេ អតីតំ — ម . នាំមកនូវរឿង ដែលកន្លងទៅហើយ ។

នរនាថ — ម . អ្នកជាទីពឹងរបស់នរជន ជាព្រះនាមហៅ ព្រះរាជា ជាម្ចាស់ផែនដី ។

នរិន្ទ — ម . ( សំ នរេន្ទ្រ ) អ្នកធំជាងនរជន , ជាព្រះនាមព្រះរាជា ជាម្ចាស់ផែនដី ។

នរបតី — ម . ម្ចាស់នៃនរជន ម្ចាស់នៃមនុស្ស ។

នាថ — ម . សំ . អធិបតី , ម្ចាស់ . ចៅហ្វាយនាយ ដែលជា



ទីពឹងជាទីពំនាក់ ឧ . នាងនាថបីបុត្រ បំពេលំអុកដោយពាក្យផ្អែមថា ឱកូនមាសម្តាយ ចូរដេកឆាប់រាំ ម្តាយនឹងយាត្រា ទៅរកភោជន ។

នារីបរិវារ — ម . ស្រីជាបរិវារ ។

និរទុក្ខ — ម . ឥតទុក្ខ . រកទុក្ខគ្មាន ។

និរទោស — សំ . ឥតទោស , រកទោសគ្មាន ។

និរភ័យ — សំ . ឥតភ័យ , រកភ័យគ្មាន ។

និមល - និម្មល - និម៌ល — ម . សំ . ឥតមន្ទិល , រកបន្ទិលគ្មាន ។

និរយេសតយា — សំ . ឥតមានភ័យ , ឥតមានហេតុដែលនាំឲ្យភ័យ ឲ្យខ្លាច ។

ប

បនភាគគតិ — ប . បទដំណើរក្អែក , ជាឈ្មោះបទ ១ យ៉ាង ។

បនភុជង្គលីលា — ប . បទដំណើរភុជង្គ , បទដំណើរនាគ ។

បនពំនោល — ខ . បទពោល ។

បនព្រហ្មគីតិ — ប . បទចម្រៀងព្រហ្ម ជាឈ្មោះបទ ១ យ៉ាង ។

បទុមរាគ — ម . ព័ណ៌ផ្កាឈូក , កែវផ្កាឈូក ត្បូងក្រហម ។

បរទេស — ម . ប្រទេសដទៃ , ប្រទេសក្រៅ ។

បរពល — ខ . ដេញពល , កេណ្ឌពល , ប្រមូលពល ។

បរិភោគភ័ក្ខនានា — ម . បរិភោគចំណីអាហារផ្សេង ៗ ។

បាឡី — ខ . បន្ទប់នៅខាងកន្សែសំពៅ ( ហៅថា

បាឡី ) ។

**បុរសរ័តន៍** សំ បុរសកែវ, បុរសប្រសើរអាចឲ្យសេចក្តីប្រាថ្នាសម្រេចបាន ហាក់ដូចជាកែវមណីជោតិ ។

**បិណ្ឌា** ( ម. បិឡ្ឌ ) បៀតបៀន ។

**បុត្រទ្វេហារ** សំ. (ភ្លាយ ) កូនពីរ, កូនទាំងពីរ ។

**បុប្ផា** ម. (សំ. បុស្បា ) ផ្កា (ផ្កាឈើទូទៅ ) ។

**បុស្ប រំលេច** សំ, បុស្ប, ខ. រំលេចផ្កា ។

**បុរាណ ជាតិ** ប បុរាណជាតិ ជាតិមុន. ជាតិចាស់ ។

**បូរ** ១. "សម្គាល់" ដូចពាក្យថា បូរពុត គឺសម្គាល់ពុត, ដូច សេចក្តីថា លួចឡើងបកទូល ដោយបូរទៀងទាត់ ។

**បៃមន់** ( សៀម ) ស្លឹកបន , ជាឈ្មោះហៅគ្រឿងហែរបស់ស្តេច មួយយ៉ាង សណ្ឋានដូចស្លឹកមន ឬ ដូចផ្លិតព្រះសង្ឃរាជាគណៈមានដងវែងសម្រាប់កាន់ រូបប្រហែលគ្នានឹងចាមរ ។

**បាំងសៃឰ** ម. ( សៀប ) បាំងកម្តៅព្រះអាទិត្យ , ជាឈ្មោះហៅគ្រឿងខ្ពស់មួយយ៉ាង សណ្ឋានដូចស្លឹកបនដែរ តែ រូបធំហានដងវែង សម្រាប់កាន់ សៀបហៅបាំងស្បែ ។

**ប្រគិត** ខ. ញឹក, ជិតគ្រៀប, ដេរដាស ។

**ប្រណិធាន** សំ. តាំងចិត្តប្រាថ្នាចំពោះ ។

**ប្រតិព័ន្ធ** សំ. ( ម. បដិពទ្ធ មានចិត្តជាប់ចំពោះ,ស្រឡាញ់ ) ។

**ប្រុះ** ខ. ភ្លឺប្រុះ ភ្លឺផ្លា , ភ្លឺច្បាស់ ។



ព

**ពន្ធទិជនី** ( រាជសព្ទ ) បក់ផ្លិតវីជនី.បក់ផ្លិត ។

**ពនិតា** (ម. វនិតា ) ប្រពន្ធ ។

**ពលព្រឹន្ទ** ម. ពល = ពល , សំ . ព្រឹន្ទ = ពល ។

**ពិឃាត** ម. សម្លាប់ ។

**ពេជ្ឈឃាត** ម អ្នកសម្លាប់មនុស្សទោស ។

**ពសុធា** សំ. ម. ផែនដី. ពិភពលោក ។

**ពាធា** ម. បៀតបៀន , យាយី ,សង្កត់ ,គ្របសង្កត់ ប្រហារ , សម្លាប់ ។

**ពានព្រះស្រី** (រាជសព្ទ) ពានព្រះដឹប ពានស្លា , ពានព្រះស្រីស្នង ពានបារី ។

**ពិលាស** សំ . ល្អ , យាងឃាស , កែក្រាយ , លំនាំកែក្រាយ , ញៀងញ៉ង , លំនាំល្អាយល្អង ។

**ពុទ្ធង្កូរ** ម . កំពូលព្រះពុទ្ធ , ព្រះពុទ្ធដ៏ជាកំពូល ជាឈ្មោះហៅពោធិសត្វ ។

**ពុទ្ធឱស្ឋ** សំ . (ម . ពុទ្ធឱដ្ឋ) ព្រះឱស្ឋរបស់ព្រះពុទ្ធ ។

**ព្រមាន** ១ . ប្រាប់ឲ្យដឹង , ស្មើឲ្យដឹង ។

**ព្រាហ្មណ៍ព្រឹទ្ធ** សំ . ប្រាហ្មណ៍ចាស់ ។

**ព្រឹត្ត-ព្រត** សំ . ប្រព្រឹត្ត ប្រព្រឹត្តវត្ត ។

**ព្រះអង្គសីហនាទ** ១ . ម . ព្រះអង្គយាងគគាតហាក់ដូចដំណើររាជសីហ៍ ។

ភ

ភិម ង្គល (ប. អភិបង្គល) ជាមង្គលដ៏ក្រៃពេក ។

ភូធរ ម. អ្នកទ្រទ្រង់ផែនដី, ស្តេចម្ចាស់ផែនដី ។

ភូមិនាថ ម. អ្នកជាទីពឹងរបស់ផែនដី ជាព្រះនាមហៅស្តេចម្ចាស់ផែនដី ។

ម

មង្គលហត្ថី ម. ដំរីមង្គល ( គឺដំរីព្រះទីន័ងរបស់ស្តេច ) ។

មហិច្ឆា ម. សត្វក្របី ។

មច្ឆា ម. ត្រី ( ត្រីគ្រប់ប្រភេទ ) ។

ម្រាំង ១. ម្ល៉ឹង, កាលណា, ម្តេចឡើយ ២. ខំបងតែងកអង្គ ម្រាំងនឹងបានរស់ជនា ។

យ

យាយី ខ. បៀតបៀន. កោសរូស ។

រអាម ខ. ឈើសង្កៀរ ខ, រអាមបាតជើង ។

រតនាពិពិធ ម. កែវផ្សេងៗ, ផ្សេងៗ ដោយកែវ ។

រតនមន្ទីរ ម. មន្ទីរកែវ, ផ្ទះកែវ ។

រតនរាគ ប. កែវព៌ណក្រហម, ត្បូងក្រហម ។

រស់ទិស័យ ១. ហាក់ដូចរស់ ។

រាជរដ្ឋា ប. ដែនស្តេច, ប្រទេសរបស់ស្តេច ។

រាជវង្សា ប. វង្សស្តេច, អំបូរស្តេច ។

រាជសន្ទីយ៍ ព. (រាជសព្ទ) ព្រះបន្ទូលស្តេច, ស្តេចស្រីនិយាយ ។



រាជសម្បត្តិរដ្ឋា ម. រាជសម្បត្តិនិងប្រទេស ។

រាជអមច្ចា ម. អាមាត្យរបស់ស្តេច ។

រូបកល្យាណា ម. រូបល្អ, ល្អរូប, រូបគួរស្រឡាញ់ ។

រូបហាន ១. ដូច, បីដូច ។

ល

លោកុត្តរា ម. ផ្លូងផុតលោក, របស់ដ៏លើសលែងលោក ។

ល្ងំ ១, រណោង, រគោង, ព្យរល្ងំ ។

វ

វរកល្យាណា ម. ល្អប្រសើរ ។

វរជាយា ម. ប្រពន្ធដ៏ប្រសើរ ។

វរពោធិញ្ញាណា ម, ប្រាជ្ញាជាគ្រឿងត្រាស់ដឹងដ៏ប្រសើរ ។

វុឌ្ឍិចេស្តា សំ. ចម្រើនចេស្តា ។

ស

សង្កា ម. សំ. សេចក្តីសន្ទិះ, សេចក្តីសង្ស័យ ។

សត្ថាអគ្គោ ម. ព្រះពុទ្ធជាសាស្តាកំពូលក្នុងលោក ។

សព្វទិវា ម. សព្វថ្ងៃ, រាល់ថ្ងៃ ។

សម័យ (ស : ម៉ៃ) ន. (សំ. ម. សមយ) កាល, ពេល ឬវេលា, គ្រា ; វេលាដែលស្រួល, ដែលត្រូវទំនង ; គតិ ; ទំនៀម, ទម្លាប់ ; វិធី, បែប, ប្រើ ; គ្រឿងសង្កេត, សញ្ញា ; ពាក្យប្រៀនប្រដៅ ; មុខការ ; ហេតុ, ការណ៍, គោលចារីក ។

**សម្ហា** អ. ប្រពៃ. គាប់ ។

**សម្ភារ** អ. សេចក្ដីកសាងសន្សំ, បារមីសម្ភារ. សាង
បារមី ។

**សម្រិទ្ធិ** សំ. (ម. សមិទ្ធិ) សេចក្ដីសម្រេច ។

**សាទរៃ** (សៀម) ស្រីបម្រើ ។

**សិរសំ** ម. (សិរ, សិរសា) ក្បាល ។

សិលាមង្គល ម. ថ្មមង្គល ។

សុព័ណ៌បាទុក សំ. (រាជសព្ទ) ស្បែកជើងមាស (គឺស្បែកជើង
សម្រាប់ស្ដេចទ្រង់) ។

សុភមិត្រ សំ. ម.. សុភមិត្រ មិត្តល្អ ជាព្រះនាមស្ដេចផែនដី
ក្នុងរឿងនេះ ។

សុវណ្ណកេត្រា ម. ខ. សំពៅមាស, កេត្រាមាស ។

ស្វម័យ ឬ ស្វអៃ សំឡេង, សម្ដី ។

សួគ៌ាល័យ សំ. លំនៅគឺឋានសួគ៌ ឋានសួគ៌ ។

សួគ៌សោឡសំ សំ. សួគ៌ ១៦ ជាន់

សៀងស្វរហាន
ភ្លេងតូរ្យតន្ត្រី } ខ, សំ. ស្វរសំឡេងដូចភ្លេងតូរ្យតន្ត្រី ។

សែនទី ១. ទេវជាសែន. ជាងសែន ។

សោឡសឆ្នាំ ១៦ ឆ្នាំ ។

សោភ័ណា-សោភា ម; ល្អ

សោយវិលាល័យ ខ. (រាជស័ព្ទ) ស្ដេចសុគត ។



ស្តឹមស្តៃ ខ.ធំសំបើម ; ធំស្តឹមស្តៃ ។

ស្មសាន (សំ. ស្មៈសាន ម. សុសាន) ខ្មែរប្រើជាសំឡេងថា
"សំសាន", ទីដុតខ្មោច ,ទីចោលខ្មោច, ទីស្ងាត់ ។

ស្មាធិការនា ម. សមាធិការនា, ចម្រើនសមាធិ ចម្រើនក្នុងផ្លូវស្លាប់។

ស្នេរ ១. ស្នេហ៍. អ្នកកត់ត្រា អ្នកសរសេរ, ស្នេរស្នាស្មើ ដោយ
ស្នេហ៍ព្រះយមរាជ ។ ២.វានេះស្នេរស្នា ចិត្តកាចពាលា។

ស្តុតី សំ. ស្តុតិ, ម.ថុតិ ស្ញុតសរសើរ ( សរសើរបារមី ។

## ហ

ហត្ថីវរលក្ខណ៍ ម. ដំរីមានលក្ខណ:ដ៏ល្អ ។

ហ័តហោង ខ. ព្រៃធំ. ព្រៃស្ងាត់ ។

ហាវហាន ខ. ក្លៀវក្លា. ក្លាហាន. អង់អាច ។

## អ

អក់រយាយ ខ.ស្រីចាស់ទុំ; ពួកស្រីចាស់ៗ ដែលមាន
បណ្ដាស័ក្តិ នៅធ្វើរាជការក្នុងផ្នែកកាន់
កាប់ពួកស្រី ៗ ។ នៅក្នុងព្រះរាជវាំង ។

អនន្ត ម. រកទីបំផុតគ្មាន, ច្រើន, រាប់មិនអស់ ។

អនន្តវសេដ្ឋ ម. ប្រសើររកទីបំផុតគ្មាន ។

អនេក ម. មិនតែ ១, ច្រើន ។

អបលក្ខណ៍ ម.ខាតលក្ខណ៍, ឥតលក្ខណ៍, គ្មានបុណ្យ ។

អប្រិយ សំ. មិនគួរស្រឡាញ់, អាក្រក់ ។

អប្សរ សំ . ស្រីអប្សរស្រីសួគ៌ . បុរាណប្រើជាអក្សរ ។

អម្ពរ ម . មេឃ . អាកាស ។

អភិរម្យ ម . គួរជាទីត្រេកអរក្រៃពេក , ជាឈ្មោះគ្រឿង ខ្ពស់មួយយ៉ាង ។

អសារ ប . ឥតខ្លឹមសារ , ឥតអំពើ ។

អស្សតរ ម . សេះលឿន សេះអស្សតរ ។

អស្សពាហ៍ សំ - អស្វ (ខ្មែរប្រើជាអស្សពាហ៍ ហើយក្លាយ ទៅជាអស្សពាហ៍ក៏មាន) សេះ ។

អសុភមិត្រ សំ (ម អសុភមិត្ត) មិត្រមិនល្អ ជានាម ស្តេចឧបរាជក្នុងរឿងនេះ ។

អធោ សំ . ទីរហោស្ថានទីដាច់ស្រយាលព្រៃស្ងាត់ ។

អា

អាយុវណ្ណ ប . អាយុនិងព័ណ៌សម្បុរ ។

ឥ

ឥស្សរស័ក្តិ (សំ . ឥស្សរស័ក្តិ) ស័ក្តិធំ , អំណាចធំ , ខ្មែរ ប្រើឥស្សរស័ក្តិ ។

ឯ

ឯកឥតទុតិយា ១ · ម . តែមួយឥតមានទី ២ , គ្មានពីរប្រៀប ។

ឱ

ឱរស សំ . ម. កូនប្រុស (ជាឈ្មោះចំពោះហៅកូន ប្រុស ១ យ៉ាង) ។